-លោក ញ៉ែន ស៊ី នាយកដ្ឋាន នគរោបនីយកម្ម និងលំនៅដ្ឋាន សមាជិក

-លោក ហុខ ណារ៉ា នាយកដ្ឋាន នគរោបនីយកម្ម និងលំនៅដ្ឋាន សមាជិក

-លោក ធា ចំនួលីដា ប្រធានសហគ្រាសសិក្សាស្រាវជ្រាវគូរប្លង់ សមាជិក

**ប្រការ ២ :** អនុគណៈកម្មការនេះមានភារកិច្ច ជំនួយការជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដើម្បីសិក្សាស្រាវ ជ្រាវកែលំអពង្រឹងគុណភាពនៃសំណង់ ដែលសាងសង់ធានាបាននូវភាពមាំ និងជួយជំរុញបន្តការងារសាងសង់ព្រះសក្យមុនីចេតីយ៍អោយ បានសំរេចល្អប្រសើរតាមព្រះរាជតំរិះ របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

-សមាជិកអនុគណៈកម្មការទាំងអស់ត្រូវរួមប្រជុំ និងចូលរួមធ្វើការងារ តាមការអញ្ជើញរបស់ប្រធានអនុគណៈកម្មការ និងតាមការណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**ប្រការ ៣ :** លោកអគ្គនាយក នាយកខុទ្ទកាល័យត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
**អ៊ឹង គៀត**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤*

## ប្រកាសលេខ ៣៨០៩ ស.ក.ដ.ជ
## ស្តីពីការធ្វើអាជីវកម្មដឹកជញ្ជូនកុមារសិស្សសាលា

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ ចុះថ្ងៃទី ១០ តុលា ឆ្នាំ ១៩៩២ ស្តីពីការធ្វើអាជីវកម្មដឹកជញ្ជូនអ្នកដំណើរតាមរថយន្ត

-យោងតាមសារាចរណែនាំលេខ ០០២ សរណនគមគពយ ចុះថ្ងៃទី ១៨ ធ្នូ ១៩៨៩ កំណត់ការងារគ្រប់គ្រងយាន ជំនិះផ្លូវគោក និងផ្លូវទឹក

-យោងតាមសេចក្តីត្រូវការចាំបាច់របស់សង្គម

**សំរេច**

**ប្រការ ១ :** រថយន្តគ្រប់ប្រភេទរបស់គ្រឹះស្ថានសិក្សារាងកជន ឬរដ្ឋ សំរាប់ដឹកជញ្ជូនកុមារតូចៗពីផ្ទះមកសាលាពីសាលាមកផ្ទះ ឬ នៅពេលមានកម្មវិធីដំណើរកំសាន្ត ត្រូវអនុវត្តតាមបទបញ្ញត្តិដូចតទៅ

**ប្រការ ២ :** បទបញ្ញត្តិដឹកជញ្ជូន :

ក-នៅពេលធ្វើចរាចរ ដាច់ខាតត្រូវអោយកុមារអង្គុយទាំងអស់គ្នា ។ ហាមកុមារងើតក្បាល រឺលូកដៃចេញក្រៅតាមបង្អួច រឺអង្គុយនៅក្បែរមាត់ទ្វាររថយន្ត ។

ខ-ត្រូវមាន “ អ្នកការពារកុមារ ” យ៉ាងហោចណាស់មួយនាក់ជាមនុស្សពេញវ័យដោយមិនរាប់បញ្ចូលអ្នកបើកបរឡើយ ។ អ្នកការពារកុមារត្រូវអង្គុយនៅមាត់ទ្វារ រថយន្ត ។ ពេលកុមារចុះពីរថយន្ត អ្នកការពារត្រូវនាំកុមារចុះអោយដល់ក្នុងរបងផ្ទះដោយ សុវត្ថិភាព ។

គ-ទ្វារសំរាប់កុមារចុះឡើង រថយន្តត្រូវដាក់ទ្វារនៅខាងស្តាំ មានគន្លឹះបើកពីខាងក្រៅរថយន្ត រឺមានប្រព័ន្ធបញ្ជាពី កន្លែងអ្នកបើកបរ ។ នៅពេលបើកបរទ្វារសំរាប់កុមារ ចុះឡើងត្រូវបិទអោយជិតជានិច្ច ។

**ប្រការ ៣ :** សញ្ញាផ្សេងៗនៅលើរថយន្ត :

ក-ត្រូវសរសេរលើជញ្ជាំងទ្វាររថយន្តនូវចំណុះផ្ទុក ចំនួនកុមារ និងមនុស្សពេញវ័យដោយគិតទម្ងន់ជាមធ្យម ៣៥ គីឡូក្រាមក្នុងមួយនាក់ ។

ខ-នៅជញ្ជាំងសងខាងនៃរថយន្ត ត្រូវសរសេរឈ្មោះរបស់សាលាជាអក្សរជាតិដែលមានកំពស់អក្សរ ២០ ស.ម កំរាស់អក្សរ ២.៥ ស.ម ហើយជារាងអក្សរជ្រុង និងមានអក្សរឡាតាំងនៅពីក្រោមដែលមានកំពស់ ១០ ស.ម និងកំរាស់ អក្សរ ១ ស.ម និងកំរាស់អក្សរ ១ ស.ម ។ ចំពោះពណ៌អក្សរ ត្រូវយកពណ៌ស រឺខ្មៅ ។

នៅលើកញ្ចក់ក្រោយរថយន្តផ្នែកខាងលើ ត្រូវសរសេរអក្សរ “ ដឹកជញ្ជូនកុមារ ” អក្សរមូលពណ៌ក្រហមកំពស់ ១៥ ស.ម កំរាស់អក្សរ១.៥ ស.ម ។ អក្សរ “ ដឹកជញ្ជូន កុមារ ”

ត្រូវប្រើដោយក្រដាសចាំងពន្លឺនៅពេលយប់ ។ ផ្នែកខាងក្រោមត្រូវមានសញ្ញារាងបួនជ្រុងផ្ទៃពណ៌លឿងមានជាយខ្មៅព័ទ្ធជុំវិញនិងមានរូបកុមារពីរនាក់កាន់ដៃគ្នាពណ៌ខ្មៅ

ប្រការ ៤ : ត្រូវធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសប្រាំមួយខែម្តងអោយបានទៀងទាត់តាមរយៈពេលកំណត់ដូចមានចែងនៅក្នុងសារាចរណែនាំលេខ ០០២ សរណនគមតពយ ចុះថ្ងៃទី ១៨ ខែ ធ្នូ ១៩៨៨ ។

ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រូវធ្វើនៅ :

-អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ចំពោះរថយន្តរបស់គ្រឹះស្ថានសិក្សាដែលមានទីតាំង នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ។

-មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត-ក្រុង ចំពោះរថយន្តរបស់គ្រឹះស្ថានសិក្សាដែលមានទីតាំងនៅតាមខេត្ត- ក្រុង ។

ប្រការ ៥ : ត្រូវមានលិខិតអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូនកុមារសិស្សសាលាដែលចេញដោយ :

-អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន ចំពោះរថយន្តរបស់គ្រឹះស្ថានសិក្សាដែលមានទីតាំង នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ។

-មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត-ក្រុង ចំពោះគ្រឹះស្ថានសិក្សាដែលមានទីតាំងនៅតាមខេត្តក្រុង

ប្រការ ៦ : សេចក្តីប្រកាសនេះចូលជាធរមានបញ្ញត្តិចាប់ពីពេលចុះហត្ថលេខាតទៅ

ប្រការ ៧ : លោកអគ្គនាយកនៃនាយកខុទ្ទកាល័យ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃប្រកាសនេះ អោយមានប្រសិទ្ធភាព ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន
ហត្ថលេខា និង ត្រា
**អ៊ឹង ហៀក**

***